តុលាការ
ខេត្តសៀមរាប-ឧត្តរមានជ័យ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៤១០ ចុះថ្ងៃទី ១១
ខែ កក្កដា ឆ្នាំ ២០០៥
សាលក្រម
លេខ ០២ "ឃ" ចុះថ្ងៃទី ២០
ខែ មករា ឆ្នាំ ២០០៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប នាថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

សាលក្រមនេះចូលជាស្ថាពរ ចាប់ពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
ដោយគ្មានភាគីណាចូលមកប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។
សៀមរាប,ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦
**ក្រឡាបញ្ជី**
ហត្ថលេខា និង ត្រា [redacted]

**ដើម្បីជំនុំជំរះ :**

សំណុំរឿងព្រហ្មទណ្ឌលេខ ៤១០ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ

១-ឈ្មោះ **ភ ចធ** ភេទស្រី អាយុ ៤៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិទ្រាំងខាងត្បូង ឃុំមិនចាំ ស្រុកព្រៃវែង ខេត្តតាកែវ កិរតវប្បធម៌មិនចេះអក្សរ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង មុខរបរលក់ផ្លែឈើ ប្តីឈ្មោះ **ច ម** មានកូន ០៤នាក់ ឪពុកឈ្មោះ **ឈ** (ស) ម្តាយឈ្មោះ **ឈ យ** (រ) ទោសពីមុន *គ្មាន* ។

ចាប់ខ្លួនថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ ។

ឃុំខ្លួនថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ ។

២-ឈ្មោះ **ឈរ សឈរ** ភេទស្រី អាយុ ២០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចុងកោះ ឃុំចុងកោះ ស្រុកកោះឧកញ៉ាតី ខេត្តកណ្តាល កិរតវប្បធម៌ថ្នាក់ទី៣ថ្មី សាសនាព្រះពុទ្ធ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិចុងកោះ ឃុំចុងកោះ ស្រុកកោះឧកញ៉ាតី ខេត្តកណ្តាល មុខរបរគ្មាន ប្តីឈ្មោះ **ឃ ទឈរ** មានកូន ០២នាក់ ឪពុកឈ្មោះ **ឱ ចរ** (ស) ម្តាយឈ្មោះ **ប ច** (រ) ទោសពីមុន *គ្មាន* ។

-ចាប់ខ្លួនថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៥



Scanned with CamScanner

-ឃុំខ្លួនថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥

ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥ ។

បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

ដោយមានលោក **រាឃ ម៉ុនឆៀន** ជាមេធាវីការពារសិទ្ធិជនជាប់ចោទ **ភ ចធ** ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ឃ មល** ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ នៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។

## <u>ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ</u>

កាលពីថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៥ ឈ្មោះ **ភ ចធ** មានឈ្មោះ **ឈា សឈា** ឈ្មោះ **ម រឈា** ហៅ **នឈា** និង ឈ្មោះ **ឌ ឆ** ហៅ **គ** មកពីខេត្តបាត់ដំបង ដេកស្នាក់នៅផ្ទះសំណាក់ឥន្ទ្រទេវីបានរៀបចំគំរោងដើម្បីទំលាក់ សំណរ ដូរគ្រឿងអលង្ការតាមទីប្រជុំជន និង តាមផ្សារដែលមានមនុស្សច្រើន ដោយឈ្មោះ **ម រឈា** ហៅ **ឈឈា** ជាអ្នកបែងចែកកំលាំងអ្នកណាត្រូវធ្វើអ្វី ។ លុះដល់ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥ វេលាម៉ោង ៨:០០ព្រឹក ជនទាំង ០៤នាក់ខាងលើបានចេញធ្វើសកម្មភាពនៅចំណុចផ្សារលើធំថ្មី ដោយបានជួបនាង **ឃ មល** ជាជនរងគ្រោះ បានពាក់គ្រឿងអលង្ការច្រើនកំពុងដើរទិញម្ហូប ពេលនោះនាង **ឈា សឈា** បានដើរតាមពីក្រោយរីឯ ឈ្មោះ **ឌ ឆ** ហៅ **គ** បានប្រើល្បិចធ្វើជាជ្រុះបាត់ប្រាក់ចំនួន ២.០០០$ "ពីរពាន់ដុល្លាសហរដ្ឋអាមេរិក" ហើយធ្វើជាសួរទៅនាង **ឈា សឈា** ថាបានរើសប្រាក់វាដែរ ឬ អត់ នាង **ឈា សឈា** បានប្រាប់ថាមិនបានធ្វើទេ ។ ភ្លាមនោះ ឈ្មោះ **ម រឈា** ហៅ **ឈឈា** បានប្រើល្បិចធ្វើជាដើរមកជិតនាង **ឈា សឈា** ហើយនិយាយប្រាប់ **ឈា សឈា** ថា បើរើសបានរបស់គេហើយអោយទៅគេវិញទៅ ។ ក្រោយមកនាង **ឈា សឈា** បានប្រើល្បិចធ្វើជារញ៉ីរញ៉ូរមកឱ្យនាង **ឃ មល** ជួយអោយនិយាយប្រាប់នាង **ឃ មល** ថាវារើសបានប្រាក់ច្រើនណាស់ជួយនាំវាចេញពីផ្សារផង វានឹងអោយសគុណ រំពេចនោះនាង **ភ ចធ** ដែលនៅចាំមើលនោះបានរត់ធ្វើជាមកជួយនាំយកនាង **ឈា សឈា** ជាមួយ **ឃ មល** ។ ពេលជិះម៉ូតូឌុបទៅដល់ តាមផ្លូវ ៦០ម នៅម្តុំហ៊ុមស័ង្កសីជនទាំង ០២នាក់បាននាំនាង **ឃ មល** ចូលទៅក្នុងព្រៃស្ងាត់ចម្ងាយពីផ្លូវ ៦០ម ប្រហែល ១០០ម ទើបនាង **ឈា សឈា** បានលូកហោប៉ៅខោយកកញ្ចប់ក្រណាត់កាំម្ទីពណ៌ក្រហម ដែលមានកូនកាបូបមួយនៅក្នុងនោះ ។ បន្ទាប់ពីរូតកាបូបទើបឃើញខ្សែកប្រាក់ជ្រលក់ទឹកមាសទម្ងន់ ០៥ តំឡឹងមួយខ្សែព្រមទាំងមានសំបុត្រទិញលក់មាសមួយសន្លឹកដែលសរសេរដាក់ចំនួនទឹកប្រាក់ជាង ២.០០០ដុល្លា "ពីរពាន់ដុល្លាសហរដ្ឋ" ដែលពួកវាបានរៀបចំ ជាស្រេចពេលនោះនាង **ឈា សឈា** បានកុហកថាមាស ។ ដោយចែកគ្នាមិនកើត ព្រោះតែខ្សែកធំមិនអាចបំបែកបាននាង **ឈា សឈា** និង នាង **ភ ចធ** បានប្រើនាង **ឃ មល** អោយទៅលក់ខ្សែកក្រឡែនោះ តែមុនពេលទៅលក់ ដើម្បីអោយជឿទុកចិត្តទាំងអស់គ្នានាង **ឈា សឈា** បាននិយាយអោយនាង **ឃ មល** ជឿលង់ថា នឹងបានចំណែក ០២តំឡឹង មាសពីខ្សែកធំនោះ ហើយយល់ព្រមដោះខ្សែកមាស សុទ្ធមួយខ្សែរម៉ូតអង្កាជីទម្ងន់ ០៥ជីមាស ដែលនាងកំពុងពាក់តម្លៃ ២៥០ដុល្លា "ពីររយហាសិបដុល្លា" និង ខ្សែដៃ ប្លាទីនមួយខ្សែទម្ងន់ ១៦ជីតម្លៃ ៥៥០ដុល្លា "ប្រាំរយហាសិបដុល្លា" អោយទៅវា ចំណែកនាង **ភ ចធ** ជាគ្នាវាបាន ដោះខ្សែដៃក្រឡែជ្រលក់ទឹកមាសមួយខ្សែ និង ខ្សែកប្លាទិនឆ្មារមួយខ្សែអោយទៅនាង **ឈា សឈា**

ដើម្បីធ្វើឱ្យ នាង ឃា មល ជឿលង់កាន់តែខ្លាំង ។ ក្រោយពីប្រគល់គ្រឿងអលង្ការដូចការ រៀបរាប់ខាងលើហើយនាង ណា សណា ក៏លូកហោប៉ៅយកកញ្ចប់ក្រណាត់កាំម្ចីពណ៌ក្រហមផ្សេងទៀត ដែលដាក់សុទ្ធតែកំទេចសំណរចងមាត់ជង់យ៉ាងជាប់ ប្រគល់អោយ ឃា មល ។ ក្រោយមកនាង ភ ចធ បានហៅ ម រណា ហៅ ឈណា ជាគ្នាវាដែលដើរតួជាអ្នករត់ម៉ូតូឌុប១យកនាង ឃា មល ទៅផ្សារដើម្បីរំដោះយកជនរងគ្រោះចេញពីពួកវា ។ ពេលទៅផ្សារស្រាយមាត់ថង់មិនបាន ព្រោះវាចងយ៉ាងជាប់យកកន្ត្រៃកាត់ខ្សែចំណងលាតថង់មើលឃើញសុទ្ធតែកំទេចសំណរ ទើបដឹងថា ចាញ់បោកគេ ហើយក៏នាំប្អូនទៅតាមកន្លែងកើតហេតុតែរកពួកវាមិនឃើញ ។ លុះដល់ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៥ នាង ណា សណា ត្រូវសមត្ថកិច្ចចាប់ខ្លួន រីឯឈ្មោះ ភ ចធ ចាប់ខ្លួនបាននៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ ចំណែកឈ្មោះ ម រណា ហៅ ឈណា និង ឈ្មោះ ទ ធ ហៅ គ រត់គេចខ្លួន ។ ក្រោយពីចាប់ខ្លួនបានជនទាំងពីរបានឆ្លើយទំលាក់កំហុសទៅលើនាង ទ ចភ ហៅ ព និង ឈ្មោះ ស សភ ហៅ ច ថាមានពាក់ព័ន្ធក្នុងអំពើទំលាក់សំណរដូរយកមាសនេះដែរ ។ នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៥ ទើបជនទាំងពីរបានសារភាពប្រាប់ការពិតថា នាង ទ ចភ ហៅ ព និង ឈ្មោះ ស សភ ហៅ ច គ្មានពាក់ព័ន្ធក្នុងរឿងនេះទេ ។ ក្រោយពីការស៊ើបអង្កេតមកឃើញថានាង ទ ចភ ហៅ ព និង ឈ្មោះ ស សភ ហៅ ច គ្មានពាក់ព័ន្ធក្នុងរឿងនេះមែន ។ ខ្សែកកាឡៃជ្រលក់ពណ៌ទឹកមាសមួយខ្សែប្រវែង ៦៧ស.ម ត្រូវដកហូតទុកជាវត្ថុតាង ។

ក្នុងរឿងនេះនាង ឃា មល ជាជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១.៦០០$ "មួយពាន់ប្រាំមួយរយដុល្លាសហរដ្ឋអាមេរិក" ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ ភ ចធ បានឆ្លើយថា ខ្លួនសូមសារភាពថា ពិតជាបានចូលរួមក្នុងការប្រព្រឹត្តិយកសំណរដូរយកមាសពិតមែន ។ បក្សពួកខ្លួនមានគ្នាចំនួន ០៤នាក់មានខ្លួនមួយ ឈ្មោះ ណា សណា ហៅ ណា ឈ្មោះ ម រណា ហៅ ឈណា និង ឈ្មោះ ទ ធ ហៅ គ ដោយមានឈ្មោះ ម រណា ជាអ្នកចាត់ចែងកំលាំងអោយត្រូវធ្វើអ្វី ។ នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥ វេលាម៉ោង ៨:០០ព្រឹក ខ្លួន និង នាង ណា សណា បានមកធ្វើសកម្មភាពនៅផ្សារលើធំថ្មី ដោយឈ្មោះ ទ ធ ហៅ គ ប្រើល្បិចធ្វើជាជ្រុះបាត់ប្រាក់ ហើយនាង ណា សណា ធ្វើជាអ្នករើសបាន ហើយជាអ្នកជួយជ្រោមជ្រែងពីក្នុងអំពើនេះដែរ ។ បន្ទាប់មកខ្លួន និង ណា សណា ធ្វើជានាំជនរងគ្រោះដែលបានឮថា ណា សណា រើសបានមាសនោះចេញពីផ្សារលើ ហើយខ្លួនហៅម៉ូតូឌុប ម៉ូតូឌុបនោះគឺឈ្មោះ ឈណា និង ឈ្មោះ គ មួយគ្រឿងឌុបខ្លួន និង ណា សណា ព្រមទាំងជនរងគ្រោះ ។ ពេលយកគ្រឿងអលង្ការដែលធ្វើស៊ីពីជនរងគ្រោះលក់បានប្រាក់ហើយឈ្មោះ ឈណា បានចែកអោយខ្លួន ១៥$ "ដប់ប្រាំដុល្លា" និង ៨០០បាត "ប្រាំបីរយបាត" ។ ហើយឈ្មោះ ឈណា ប្រាប់ខ្លួនថា ចំណែកឈ្មោះ ច គេជាអ្នកយកទៅអោយត្រង់ថា ឈ្មោះ ច នោះបានទទួលប្រាក់យ៉ាងណានោះខ្លួនមិនបានដឹងទេ ។ ឈ្មោះ ច និង ឈ្មោះ ព ពេលខ្លួនធ្វើសកម្មភាពនោះពុំមានមុខឈ្មោះ ច និង ឈ្មោះ ព ទេ ឮតែឈ្មោះ ឈណា ប្រាប់ខ្លួនតែប៉ុណ្ណោះ ពេលដែលយកចំណែកទៅអោយ ។ ឈ្មោះ ច នោះខ្លួនត្រូវ ឈណា ប្រាប់ថា នៅកោះកុងតែខ្លួនមិនដឹងថា ច នោះនៅឯណាពិតប្រាកដទេ ព្រោះខ្លួនពុំដែលបានជួប ។ ចំពោះចម្លើយដែលខ្លួនបានឆ្លើយនៅដំណាក់កាលប៉ូលីស និង នៅតំណាក់កាលចៅក្រមស៊ើបអង្កេតលើកដំបូង ដែលខ្លួនបានឆ្លើយដាក់ឈ្មោះ ស សភ ហៅ ច នៅខេត្តបាត់ដំបង និង ឈ្មោះ ទ ចភ ហៅ ព នៅបាត់ដំបងនោះ គឺខ្លួនឆ្លើយតាមប៉ូលីសឈ្មោះ អ ដែលប្រាប់ខ្លួន ព្រោះគាត់ប្រាប់ខ្លួនថាឈ្មោះ ណា សណា បានឆ្លើយអស់ហើយ រឿងអីខ្លួនដែល



Scanned with CamScanner

ជាមនុស្សចាស់មិនស្គាល់ឈ្មោះ **ស សត** ខ្លួនគ្រាន់តែឆ្លើយថា អ្នកដែលទទួលចំណែកគឺ ឈ្មោះ **ច** ត្រង់ថាឈ្មោះ **ច** នោះមានឈ្មោះអ្វីទៀតខ្លួនពុំបានដឹងទេ ហើយប៉ូលីសឈ្មោះ **អ** បានប្រាប់ខ្លួនថា ឈ្មោះ **ច** នោះឈ្មោះ **ស សត** ត្រង់ថាគាត់ដឹងមកពីណានោះខ្លួនពុំបានដឹងទេ ។ ឈ្មោះ **ណ សណ** ដែលសមត្ថកិច្ចចាប់មកនោះ គឺធ្លាប់ជក់ថ្នាំញៀនប្រភេទយ៉ាម៉ា ហើយធ្លាប់ជាប់ពន្ធនាគារព្រៃសម្តង ។ ចំពោះចម្លើយដែលវាបានឆ្លើយដាក់ឈ្មោះ **ស សត** នោះគឺប៉ូលីសបានយកចម្លើយ **ណ សណ** មកមើលអោយខ្លួនស្តាប់ ហើយខ្លួនខ្លាចសមត្ថកិច្ចធ្វើបាប ខ្លួនបានឆ្លើយតាមចម្លើយ **ណ សណ** សិនទៅ ព្រោះខ្លាចប៉ូលីស ។ ឈ្មោះ **ស សត** ហៅ **ច** និង ឈ្មោះ **ទ ចត** ហៅ **ព** នៅខេត្តបាត់ដំបងនោះពុំមានពាក់ព័ន្ធក្នុងរឿងទំលាក់សំណរដូរយកមាសទេ ។

ជនជាប់ចោទឈ្មោះ **ណ សណ** បានឆ្លើយថា ខ្លួនសូមសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តអំពើយកសំណរដូរយកគ្រឿងអលង្ការគេនៅផ្សារលើធំថ្មី ខេត្តសៀមរាបពិតប្រាកដមែន ។ បក្សពួកខ្លួនដែលចូលរួមប្រព្រឹត្តអំពើនេះមានឈ្មោះ **ត ចធ** ដើរពីក្រោយខ្លួនឈ្មោះ **លណ** ភេទប្រុស និង ឈ្មោះ **គ** ធ្វើទាហាននៅខេត្តកោះកុងជាអ្នកបើកម៉ូតូឌុប ។ ឈ្មោះ **គ** ជាអ្នកដើរតួថា ជ្រុះបាត់កញ្ចប់ប្រាក់ និង ជាអ្នកសួររកកញ្ចប់លុយរបស់គាត់ ។ មុនពេលធ្វើសកម្មភាព ពួកខ្លួនដេកនៅផ្ទះសំណាក់ឥន្ទ្រទេវី ដោយឈ្មោះ **គ** និង ឈ្មោះ **លណ** ជាអ្នកបែងចែកកំលាំងអោយខ្លួនធ្វើជារើសបានប្រាក់ ចំណែកឈ្មោះ **ត ចធ** ជាអ្នកដើរពីក្រោយខ្លួន ។ លុះម៉ោង ៨:០០ព្រឹក ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥ ខ្លួន និង ឈ្មោះ **ត ចធ** បានមកផ្សារលើមុន ហើយឈ្មោះ **គ** និង **លណ** មកតាមក្រោយនៅម្តុំផ្សារត្រី ក្នុងផ្សារលើឈ្មោះ **ត ចធ** នៅពីក្រោយជនរងគ្រោះ ចំណែកខ្លួននៅពីមុខជនរងគ្រោះ ឈ្មោះ **គ** បានធ្វើជាមកសួរខ្លួនថា "មីអូនមានបានរើសកញ្ចប់លុយពូទេ ចាំពូជូនសគុណ ខ្លួនក៏ប្រាប់ថា "អត់ទេ" ពេលនោះឈ្មោះ **គ** ក៏ដើរចេញផុតទៅ ក្រោយមកខ្លួនបានប្រើល្បិចធ្វើជាភ័យរញ៊ីរញ៉ូវប្រាប់ជនរងគ្រោះថា "រើសបានកញ្ចប់ប្រាក់ "ព្រោះឃើញជនរងគ្រោះពាក់គ្រឿងអលង្ការច្រើន ។ ពេលនោះខ្លួនបានខ្សិបប្រាប់ជនរងគ្រោះថា ជួយជូនខ្លួនចេញទៅក្រៅកុំប្រាប់គេ ។ ភ្លាមនោះឈ្មោះ **ត ចធ** បានធ្វើនិយាយថា បើរើសរបស់គេបានអោយគេវិញទៅ ។ ខ្លួនក៏និយាយថា កុំឮមាត់ចាំខ្លួនអោយសគុណ ។ ខ្លួន ជនរងគ្រោះ និង **ត ចធ** ក៏នាំគ្នាចេញពីផ្សារលើដោយជិះម៉ូតូឌុប ០២គ្រឿង ខ្លួនជិះជាមួយជនរងគ្រោះឈ្មោះ **ត ចធ** ជិះតែម្នាក់ឯង ។ ខ្លួនបានអោយម៉ូតូឌុបជិះទៅផ្លូវ ៦០ម៉ែត្រម្តុំរង្វង់មូល ហើយឈប់នៅទីនោះនាំគ្នាចុះទៅក្រោម ហើយស្រាយកញ្ចប់លុយដែលរើសបាន ខ្លួនដាក់ជាប់ខ្លួនទៅជាស្រេចធ្វើជាស្រាយមើល ហើយឃើញខ្សែកមាសទម្ងន់ ០៥តំឡឹងនៅក្នុងនោះ ខ្សែកនោះ គឺឈ្មោះ **លណ** ទិញមកពីប្រទេសថៃជ្រលក់ទឹកមាស ហើយនៅក្នុងថង់កញ្ចប់មាសនោះមានក្រដាសទិញមាស ដែលសរសេរដាក់ថា ជាង ២.០០០$ ។ ក្រោយមកខ្លួនក៏ប្រើល្បិចថា ធ្វើម៉េចបើរបស់នោះធំជាប់គ្នាយ៉ាងនេះចែកគ្នាម៉េចកើតបើអញ្ចឹងបងឯងយករបស់នេះទៅលក់ទៅ ហើយដើម្បីអោយមានការទុកចិត្តតើមានអ្វីដាក់ជាមួយខ្លួន ពេលនោះជនរងគ្រោះមិនស្គាល់បានដោះខ្សែកមាសមួយខ្សែទម្ងន់ ០៥ជី "ប្រាំជី" និង ខ្សែដៃប្លាទីនទម្ងន់មួយតំឡឹងហុចមកអោយខ្លួន ចំណែកឈ្មោះ **ត ចធ** បានដោះខ្សែកប្លាទីនឆ្លារមួយខ្សែ និង ដោះខ្សែដៃមាសកាឡៃហុចមកអោយខ្លួនធ្វើអោយម្ចាស់ជាជនរងគ្រោះ ហើយខ្លួនក៏ជិះម៉ូតូមកក្រៅវិញទៅ ។ មាស និង ខ្សែដៃនោះលក់ដោយ **ត ចធ** ខ្លួនទទួលបាន ៣០$ "សាមសិបដុល្លា" ។ ឯឈ្មោះ **ស សត** ហៅ **ច** និង ឈ្មោះ **ទ ចត** ហៅ **ព** នោះពុំបានមកធ្វើសកម្មភាពជាមួយពួកខ្លួនទេ តែពេលចែកចំណែកត្រូវឈ្មោះ **លណ** និង ឈ្មោះ **គ** ថាយកទៅអោយឈ្មោះ **ច** និង ឈ្មោះ **ព** ត្រង់ថាយកទៅអោយ ឬ មិនអោយឈ្មោះ **ច** និង ឈ្មោះ **ព** នោះខ្លួនពុំបានដឹងទេ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ឆ មល** បានឆ្លើយថា កាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥ វេលាម៉ោង

៨:៣០នាទីព្រឹក ខ្លួនបានដើរទៅផ្សារលើធំថ្មីដើម្បីទៅទិញម្ហូប ។ ខ្លួនបានដើរទៅកន្លែងផ្សារត្រីក៏បានជួបមនុស្សស្រីម្នាក់មាឌធំអាយុប្រហែលខ្ទង់ ៤០ឆ្នាំ បានមកសួរខ្លួនថា មានបានរើសមាសរបស់វា ឬ អត់? ខ្លួនក៏ឆ្លើយថា "អត់ទេ" ភ្លាមនោះមានមនុស្សស្រីម្នាក់មាឌតូចស្គមតូចបានឆ្លើយថា "ខ្លួនវារើសបាន" ពេលនោះស្រីនោះបាននិយាយថាអោយជួយនាំវាអោយផុតពីផ្សារផង ហើយស្រីនោះមានសភាពញ័រញ៉័រទាំងដៃក៏ញ័រដែរ វាបាននិយាយតិចៗថាអោយជួយវាទៅចាំវាអោយសគុណ ។ ខ្លួនក៏បានជួយវាចេញពីផ្សារ ដោយជិះម៉ូតូឌុបមកផ្លូវ ៦០ម៉ែត្រហួសរង្វង់មូលនៅម្តុំសង្កសីបៃតងក៏ឈប់ម៉ូតូ ។ បន្ទាប់មកខ្លួនក៏ឃើញម្នាក់ដែលរើសបានមាសចូលទៅក្នុងព្រៃ វាប្រាប់ទៅបត់ជើង ពេលចេញមកវិញម្នាក់នោះក៏ហៅខ្លួន និង ស្រីម្នាក់គ្នាវានោះទៅមុខទៀត លើកនេះចូលទៅជ្រៅជាងមុនពេលទៅនោះឆ្ងាយពីផ្លូវ ៦០ម៉ែត្រ ចម្ងាយប្រហែល១០០ម៉ែត្រ ពេលនោះស្រីនោះបានលាតកូនកាបូបតូចមួយមកបង្ហាញខ្លួននៅក្នុងកាបូបនោះ មានកូនថង់កាំម្ជីពណ៌ក្រហមចងមាត់ជាប់ វាក៏ស្រាយមាត់ថង ទើបឃើញខ្សែកក្រហមដូចមាស ខ្លួនទារវាយកមកពិនិត្យមើលវាមិនអោយខ្លួនមើលទេ ។ ពេលនោះស្រីដែលធំវ័យចំណាស់នោះបាននិយាយថា ទៅដូរមាសជាមួយខ្លួន ក្រោយមកវាក៏ថាអោយខ្លួនទៅដូរតែម្នាក់ឯងទៅ ។ មុនពេលខ្លួនទៅដូរនៅស្រីម្នាក់ ដែលតាំងខ្លួនថា រើសបានមាសនោះ គេនិយាយថា វាចែកអោយខ្លួន ០២តំឡឹង ចែកអោយស្រីម្នាក់នោះ ០២តំឡឹង ចំណែកវាយកចំនួន ០៣តំឡឹង ។ ខ្លួនក៏យល់ព្រមទៅដូរបំបែកខ្សែកនោះ ។ មុនពេលខ្លួនចេញមកដូរនោះម្នាក់ដែលមានមាឌតូចល្អិតនោះបាននិយាយថា "បើបងឯងទៅដូរ តើបានអ្វីដាក់ជាមួយខ្ញុំ ដើម្បីអោយខ្ញុំជឿទុកចិត្ត" ភ្លាមនោះគ្នាវាដែលធាត់ធំនោះបានដោះខ្សែកប្លាទីនឆ្មារមួយខ្សែ និង ខ្សែដៃមួយខ្សែអោយទៅស្រីមាឌតូចនោះ មិនដឹងថា ខ្សែដៃនោះមាស ឬ អ្វីទេ តែមើលទៅពណ៌ដូចមាស ។ ពេលនោះខ្លួនបានដោះខ្សែកមាសម៉ូតអង្កាំសដីទម្ងន់ ០៥ជី "ប្រាំជីមាស" និង ខ្សែដៃប្លាទិនមានទម្ងន់ ១៦ជី "ដប់ប្រាំមួយជី" ប្រគល់អោយម្នាក់មាឌធំដែលមានវ័យចំណាស់ ។ ពេលបានខ្សែដៃពីខ្លួនហើយ ម្នាក់ដែលមានមាឌធំនោះប្រាប់ខ្លួនថា គេមិនបានទៅដូរជាមួយខ្លួនទេ វាចាំខ្លួននៅទីនេះ អោយខ្លួនឆាប់ត្រឡប់ទៅវិញ ហើយទៅយក ខ្សែក ខ្សែដៃពីវាមកវិញ ។ បន្ទាប់មកម្នាក់ដែលមានមាឌតូចនោះ ក៏ហុចកញ្ចប់មាសមានថង់កាំម្ជីចងមាត់ជាប់មកអោយខ្លួន ហើយម្នាក់ដែលមានមាឌធាត់នោះរុញខ្លួនអោយឆាប់ទៅឆាប់បានមកវិញ ធ្វើអោយអារម្មណ៍ខ្លួនវិលវុលគិតអ្វីមិនឃើញ ។ ម្នាក់ដែលមានមាឌធំបានហៅម៉ូតូឌុបអោយខ្លួនជិះយកមាសនោះមកដូរ ពេលទៅដល់កន្លែងជញ្ជីងមាសក៏យកកន្ត្រៃកាត់ខ្សែថង់កាំម្ជី ព្រោះស្រាយមិនចេញវាចងមាត់ជាប់ ពេលកាត់រួចឃើញសុទ្ធតែសំណរទាំងអស់ ។ ពេលឃើញសុទ្ធតែសំណរក៏ផ្អើលឆោឡោឡើង ពេលនោះខ្លួនក៏ទៅតាមវាវិញ តែពេលទៅដល់រកមិនឃើញវាទេ ត្រូវពួកវាទាំងពីរនាក់គេចខ្លួនបាត់តែម្តង ។ ខ្សែដៃរបស់ខ្លួនកាលទិញខ្លួនទិញអស់ប្រាក់ចំនួន ៥៥០$ ខ្សែកមាសតម្លៃ ២៥០$ "ពីររយហាសិបដុល្លា" សរុបការបាត់បង់អស់ ៨០០$ "ប្រាំបីរយដុល្លា" ។ លុះដល់ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៥ ម៉ោង ៨:០០ព្រឹក ខ្លួនបានទៅផ្សារលើដដែល ដើម្បីទៅទិញម្ហូបទៀត ក៏បានជួបអ្នកដែលបានបោកយកគ្រឿងអលង្ការខាងលើរបស់ខ្លួនចាប់បានម្នាក់ដែលមានមាឌតូច អ្នកដែលហុចកញ្ចប់សំណរអោយខ្លួន ។ ចំណែកម្នាក់ធំដែលទទួលគ្រឿងអលង្ការរបស់ខ្លួន ពេលនោះខ្លួនឃើញវាដើរជាមួយគ្នាដែរ តែចាប់មិនបាន បានតែម្នាក់តូចតែប៉ុណ្ណោះ ។ លុះនាំខ្លួនមកដល់ព្រហ្មទណ្ឌទើបដឹងថា ស្រីម្នាក់នោះមានឈ្មោះ **ណ សណ** ហៅ **ណ** ម្នាក់ដែលមានមាឌធំនោះ ឈ្មោះ ភ

ចធ ។

ក្នុងរឿងនេះ ខ្លួនសុំប្តឹងទាមទារសំណង និង ជម្ងឺចិត្តជាប្រាក់ចំនួន ១.៦០០$ "មួយពាន់ប្រាំមួយរយដុល្លាសហរដ្ឋអាមេរិក" ។



Scanned with CamScanner

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

ជនជាប់ចោទបានសារភាពអស់ហើយ មិនខុសអ្វីពីដីកាសន្និដ្ឋានស្ថាពរ ដែលបានចែងរួចមកហើយនោះទេ តាងនាមខ្ញុំជាតំណាងអយ្យការ សូមតម្កល់បទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរដដែល ។ សង្ឃឹមថា លោកចៅក្រម និង ចេញសាលក្រមផ្តន្ទាទោសអោយបានសមស្រប និង គតិបណ្ឌិត ។

## មេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា

ឆ្លងតាមសវនាការនេះឃើញថា កូនក្តីរបស់ខ្ញុំបានឆ្លើយសារភាពអស់នូវសាច់រឿង ដែលពួកគេបានប្រព្រឹត្តជាហេតុពុំបង្កការស៊ើបអង្កេតដល់តុលាការឡើយ ។ ហេតុនេះសូមតុលាការមេត្តាជួយបន្ធូរបន្ថយទោស ដល់កូនក្តីខ្ញុំដោយក្តីអនុគ្រោះ ។

ជនជាប់ចោទបាននិយាយសំដីជាចុងក្រោយបង្អស់ថា "សូមតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនដោយក្តីអនុគ្រោះ" ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានពិនិត្យភស្តុតាង
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់អយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី
-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយបង្អស់

## តុលាការ

ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា កាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥ វេលាម៉ោង ៨:០០ព្រឹក ឈ្មោះ **ភ ចធ. ឈ សឈ** ហៅ **ឈ** ឈ្មោះ **ឪ ធ** ហៅ **គ** និង **ម រឈ** ហៅ **លឈ** បានប្រើល្បិចយកសំណរដូរយកគ្រឿងអលង្ការពីជនរងគ្រោះឈ្មោះ **ហ មល** នៅម្តុំផ្លូវ៦០ម ដោយប្រើរូបភាពថា រីសបានប្រាក់ច្រើនហើយ ក្រោយមកបន្លំអោយថង់សំណរទៅជនរងគ្រោះ ហើយត្រូវសមត្ថកិច្ចចាប់ខ្លួនឈ្មោះ **ឈ សឈ** និង **ភ ចធ** រីឯឈ្មោះ **ឪ ធ** ហៅ **គ** និង **ស រឈ** ហៅ **លឈ** រត់គេចខ្លួន ។

-យល់ឃើញថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ **ភ ចធ** និង ឈ្មោះ **ឈ សឈ** មានចែង និង ផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-ប៉ុន្តែបើពិនិត្យអោយបានដិតដល់ទៅឃើញថា ជនជាប់ចោទជាមនុស្សខ្វះការពិចារណា មានជីវភាពក្រលំបាក ហើយតែប្រព្រឹត្តបទល្មើសជាលើកដំបូង ។

-យល់ឃើញថា វត្ថុតាង មានខ្សែកកាឡៃមួយខ្សែប្រវែង ៦៧ស.ម គឺជាខ្សែក ដែលជនជាប់ចោទបានយកមកបោកបញ្ឆោតអោយជនរងគ្រោះជឿទុកចិត្តប្រាកដមែន ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីនាង **ហ មល** បានប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១.៦០០$ "មួយពាន់ប្រាំមួយរយដុល្លាសហរដ្ឋអាមេរិក" តុលាការគប្បីពិចារណាដល់បញ្ហានេះ ។



Scanned with CamScanner

## ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោស :

ក-ឈ្មោះ ក ចង ដាក់គុកកំណត់ ០១ឆ្នាំ "មួយឆ្នាំ" គិតពីថ្ងៃឃុំខ្លួន ។

ខ-ឈ្មោះ ឈា សឈា ដាក់គុកកំណត់ ០១ឆ្នាំ "មួយឆ្នាំ" គិតពីថ្ងៃឃុំខ្លួន ។

ពីបទ ឆបោក ប្រព្រឹត្តនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥ តាមមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-បង្គាប់អោយឈ្មោះ ក ចង និង ឈ្មោះ ឈា សឈា រួបរួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៩០០ដុល្លា "ប្រាំបួនរយដុល្លាសហរដ្ឋអាមេរិក" ទៅអោយឈ្មោះ ឃ មឈ ជាដើមបណ្តឹងរដ្ឋប្បវេណី ។ សុំលើសពីនេះលើកចោល ។

ក្នុងករណីគ្មានប្រាក់សងធនទណ្ឌនេះទេ ត្រូវដាក់គុកបង្ខំលើរូបកាយតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយគឺ ០២ឆ្នាំ ។

៣-វត្ថុតាងមានខ្សែកកាឡៃមួយខ្សែប្រវែង ៦៧ស.ម ត្រូវដកហូត និង បំផ្លាញចោល ។

៤-សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខតួក្តី បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ពេល ០២ខែ គិតពីថ្ងៃនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និង ត្រា**
[redacted]

**ចៅក្រមជំនុំជំរះ**
**ហត្ថលេខា និង ត្រា**
[redacted]

---

**បានឃើញ**
*សៀមរាប,ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦*
**ប្រធានតុលាការខេត្ត**
[redacted]

July 2005 – 11/2006

[redacted]:



Scanned with CamScanner